# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២ និង
# លើកទិសដៅការងារឆ្នាំ ២០២៣ របស់នាយកដ្ឋានថែទាំសុខភាពជនបទ

## សេចក្ដីផ្ដើម

ផលប៉ះពាល់នៃកង្វះអនាម័យគឺជាបញ្ហាសុខភាពសាធារណៈ ក្នុងនោះគឺការបន្ទោបង់ក្រៅបង្គន់ ទម្លាប់មិនប្រតិបត្តិអនាម័យបានបណ្ដាលឱ្យមានការចម្លងមេរោគពីលាមកមកមនុស្ស។ ផលប៉ះពាល់ដល់សុខភាពបានធ្វើឱ្យអត្រាឈឺ និងស្លាប់របស់កុមារមានកម្រិតខ្ពស់បណ្ដាលមកពីជំងឺរាកបញ្ហាកង្វះអាហារូបត្ថម្ភជាដើម។ បញ្ហាផ្សេងៗទៀតធ្វើឱ្យខាតបង់ពេលវេលាការងារនិងការរៀនសូត្រ និងបង្កើនចំណាយច្រើនក្នុងគ្រួសារលើការថែទាំសុខភាពការព្យាបាលជំងឺនិងធ្វើដំណើរមកមន្ទីរពេទ្យ។ ដើម្បីឆ្លើយតបនិងបញ្ហានេះក្រសួងអភិវឌ្ឍន៍ជនបទ ដែលមាននាយកដ្ឋានថែទាំសុខភាពជនបទជាសេនាធិការបានដាក់ចុះនូវទិសដៅក្នុងការលើកកម្ពស់អនាម័យជនបទ ដោយផ្ដល់អាទិភាពខ្ពស់លើការដឹកនាំសម្របសម្រួលសហប្រតិបត្តិការនិងតាមដានវាយតម្លៃគោលដៅធំៗបី នៃការលើកកម្ពស់អនាម័យជនបទ៖ (១).ការសាងសង់និងប្រើប្រាស់បង្គន់អនាម័យ (២).ការលាងសម្អាតដៃជាមួយសាប៊ូក្រោយពេលបន្ទោបង់និងមុនពេលបរិភោគអាហារនិង (៣).ការផឹកទឹកមានសុវត្ថិភាព។

ការផ្គត់ផ្គង់ទឹកសម្រាប់ផឹកមានសុវត្ថិភាព មានបង្គន់អនាម័យប្រើប្រាស់ និងប្រតិបត្តិអនាម័យខ្លួនប្រាណបានល្អគឺជាមូលដ្ឋានគ្រឹះសម្រាប់សុខភាព ផលិតភាពការងារ និងភាពថ្លៃថ្នូររបស់មនុស្សគ្រប់រូប។ចំណុចលើកឡើងខាងលើនេះយើងមើលឃើញថា ប្រជាជនក្រីក្រភាគច្រើនមិនទាន់ទទួលបាននូវលទ្ធភាពទាំងអស់នេះទេហើយនេះក៏ជាហានិភ័យដ៏ធំធេង ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងធនធានមនុស្សនៅក្នុងសង្គមនៃប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទត្រូវបានមើលឃើញថាបានជួយលើកកម្ពស់វិស័យសន្តិសុខស្បៀង អាហារូបត្ថម្ភជីវភាពប្រជាជន និងការសិក្សារបស់កុមារនៅក្នុងសាលារៀន។ ហេតុដូច្នេះ ដើម្បីសម្រេចបាននូវទិសដៅខាងលើនាយកដ្ឋានថែទាំសុខភាពជនបទ នឹងបន្តអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទបានកំណត់ថានៅឆ្នាំ២០២៥ប្រជាជនជនបទ១០០% និងទទួលបានការផ្គត់ផ្គង់ទឹកនិងសេវាអនាម័យដែលមានការកែលម្អប្រកបដោយចីរភាព និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យល្អ។

## I. សមិទ្ធផលសម្រេចបាន

វិស័យលើកកម្ពស់អនាម័យជនបទ បានទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាលពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងអភិវឌ្ឍន៍ជនបទ និងពីបណ្ដាអង្គការនានាដែលធ្វើការងារ

លើវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២២ការលើកកម្ពស់អនាម័យជនបទសម្រេចបានលទ្ធផលចំបងៗដូចខាងក្រោម៖

**១.សកម្មភាពការងារនាយកដ្ឋាន (ថ្នាក់ជាតិ)**

**១.១.សកម្មភាពរៀបចំប្រជុំ ចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ**

- ប្រធាននាយកដ្ឋាននិងសហការីបានរៀបចំប្រជុំ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗចំនួន១០៤លើកដោយផ្តោតសំខាន់លើ៖ ប្រជុំក្រុមការងារទឹកស្អាតនិងអនាម័យជាមួយអង្គការ Unicef និង WaterAid ដើម្បីពន្លឿនផែនការODF, ផ្តល់សម្ភារៈអនាម័យជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត, វេទិកាចែករំលែកចំណេះដឹងស្តីពីអនាម័យក្នុងបរិស្ថានប្រឈម, ចូលរួមកម្មវិធីលើកទឹកចិត្តប្រតិបត្តិមេត្រីបរិស្ថាន, ពិធីប្រកាសទទួលស្គាល់ខេត្តស្វាយរៀងនិងព្រៃវែងជាខេត្ត(ODF), កម្មវិធីប្រគួតប្រជែងសិស្សវិទ្យាល័យស្តីពីអនាម័យនិងការបង្ការរោគ, សិក្ខាសាលាស្តីពីការពិនិត្យឡើងវិញពីវឌ្ឍនៈភាពនៃការអនុវត្តច្បាប់សុខភាព ឆ្នាំ២០០៥, រៀបចំប្រជុំថ្នាក់ក្រោមជាតិស្តីពីការពន្លឿន(ODF)នៅកម្ពុជា, សិក្ខាសាលាស្ទង់មតិជាសាកលលើការវិភាគវាយតម្លៃអនាម័យនិងទឹកបរិភោគ, សិក្ខាសាលាស្តីពីការរៀបចំឯកសារកញ្ចប់ថវិកាវិនិយោគសម្រាប់គាំពារ និងអភិវឌ្ឍន៍កុមារតូច, ប្រជុំពិគ្រោះយោបល់គោលការណ៍ណែនាំជាតិស្តីពីការឧបត្ថម្ភធនសម្ភារៈអនាម័យដល់គ្រួសារក្រីក្រនៅជនបទ, ប្រជុំគម្រោងលើកកម្ពស់អនាម័យនិងផ្គត់ផ្គង់ទឹកស្អាតគិតគូដល់អាហារូបត្ថម្ភ, សិក្ខាសាលាស្តីពីការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថលសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ, ប្រជុំក្រុមការងារអភិវឌ្ឍន៍អន្តរក្រសួងលើកម្មវិធីចាប់ផ្តើមពីសុខភាពល្អ, ប្រជុំចរចារតម្លៃគម្រោងផ្គត់ផ្គង់សម្ភារៈបង្គន់អនាម័យ, សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលការអនុវត្តថវិកាកម្មវិធី, ចូលរួមវាគ្មិនសន្និសិទសារព័ត៌មានអំពីសមិទ្ធផល០៥ឆ្នាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, សិក្ខាសាលាអប់រំអនាម័យខ្លួនប្រាណស្ត្រីនិងកុមារីពេលមានរដូវសហការជាមួយEMWF, បើកវគ្គតម្រង់ទិសកម្មវិធីCLTSដល់មន្ត្រីអង្គការយូរីដូ, សិក្ខាសាលាផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥និងគម្រោងថវិកាឆ្នាំ២០២៣លើវិស័យផ្គត់ផ្គង់ទឹកនិងអនាម័យជនបទ, ចុះពិនិត្យតាមដានការប្រើប្រាស់បង្គន់អនាម័យក្នុងអង្គភាពរដ្ឋនិងសេវា ឯកជនតាមខេត្ត, ចូលរួមប្រជុំពិនិត្យវឌ្ឍនៈភាពការអនុវត្តកម្មវិធីទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទខេត្ត, សិក្ខាសាលាស្តីពីផែនការយុទ្ធសាស្ត្រជាតិការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជន បទ (២០១៤-២០២៥), ចូលរួមប្រជុំពិភាក្សាការងារគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ, ចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យសម្រាប់ជនពិការ, ចូលរួមប្រជុំពិភាក្សាការងាររៀបចំសេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យស្តីពីការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, ចូលរួមចុះពិនិត្យនិងវាយតម្លៃ ហេដ្ឋារចនាសម្ព័ន្ធខេត្តរងការខូចខាតដោយទឹកជំនន់, ប្រជុំក្រុមការងារពាក់ព័ន្ធដើម្បីកៀរគរថវិកាសម្រាប់ផ្ទៀងផ្ទាត់(ODF)ខេត្តកណ្តាល, និងរៀបចំសិក្ខាសាលាថ្នាក់ជាតិផ្សព្វផ្សាយគោលការណ៍ណែនាំការផ្ទៀងផ្ទាត់ភូមិឃុំស្រុកខេត្ត (ODF)ដើម្បីធ្វើបច្ចុប្បន្នភាពការអនុវត្តការងារអនាម័យ។

### ១.២.សកម្មភាពកម្មវិធីការគ្រប់គ្រងប្រព័ន្ធទិន្នន័យផ្គត់ផ្គង់ទឹកស្អាតនិងសុខភាពអនាម័យជនបទ(MIS)

- អនុប្រធាននាយកដ្ឋាន និងសហការីបានរៀបចំសិក្ខាសាលា ចូលរួមប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៥៦លើកដោយផ្តោតសំខាន់លើៈ សិក្ខាសាលាចែករំលែកចំណេះដឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ(MIS)បែបឌីជីថលក្នុងវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងលើកកម្ពស់អនាម័យសម្រាប់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ខេត្ត, ប្រជុំជាមួយអង្គការ Unicef និង WaterAid ពិនិត្យឡើងវិញពី Country Overview និងរបាយការណ៍"Climate resilient Wash formative evaluation", ប្រជុំចែករំលែកបទពិសោធន៍ស្តីពីការគ្រប់គ្រងប្រព័ន្ធMISរវាងកម្ពុជា និងប្រទេសណេប៉ាល់, ប្រជុំជាមួយCCCAនិងក្រុមហ៊ុនBikay ស្តីពីគម្រោងបំរែបំរួលអាកាសធាតុការបង្កើតប្រព័ន្ធMISថ្មីនិងប្រព័ន្ធ Google data studio, ប្រជុំជាមួយSWAដើម្បីស្វែងរកការគាំទ្រលើគម្រោងMIS, ប្រជុំជាមួយក្រុមការងារWaterAidស្តីពីទឹកស្អាត និងអនាម័យជនបទក្នុងការពន្លឿនសេវាទឹកស្អាតនិងអនាម័យដល់ក្រុមជនងាយរងគ្រោះ, ប្រជុំជាមួយអង្គការ Unicef/WHO ដើម្បីវាស់វែងសូចនាករទឹកស្អាតនិងអនាម័យMISសម្រាប់ឆ្នាំ២០២២, សិក្ខាសាលាស្តីពី"Solution to Action" ក្នុងការត្រៀមចូលរួមប្រជុំថ្នាក់រដ្ឋមន្ត្រីនៅប្រទេសឥណ្ឌូនេស៊ី, សិក្ខាសាលាអំពីកញ្ចប់វគ្គបណ្តុះបណ្តាលពីហានិភ័យអាកាសធាតុលើវិស័យ(WASH)សម្រាប់មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទថ្នាក់ជាតិនិងក្រោមជាតិ, ប្រជុំក្រុមការងារបច្ចេកទេសលេខាធិការដ្ឋានTWGs ដើម្បីពិនិត្យសេចក្តីព្រាងពាក់កណ្តាលអាណត្តិ NAPII, ប្រជុំពិនិត្យកែសម្រួលគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងអនាម័យស្ត្រីនិងកុមារីពេលមានរដូវ, សិក្ខាសាលាថ្នាក់តំបន់ស្តីពីការធ្វើឲ្យប្រសើរឡើងវិស័យផ្គត់ផ្គង់ទឹកស្អាតអនាម័យ និងអាកាធាតុក្នុងតំបន់, ចូលរួមប្រជុំជាមួយអង្គការដៃគូ(SWA, UNICEF, WaterAid)ដើម្បីពិនិត្យ និងវាយតម្លៃលទ្ធផលប្រចាំឆ្នាំ, វគ្គបណ្តុះបណ្តាលនៅប្រទេសសឹង្ហបុរីស្តីពីការគ្រប់គ្រងធនធានទឹកនិងព្យុះភ្លៀងដោយនិរន្តរភាព, ប្រជុំប្រមូលទិន្នន័យអត្ថប្រយោជន៍នៃការធ្វើសារពើភ័ណ្ឌទិន្នន័យនិងការគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធឌីជីថល(AIMIS), ប្រជុំស្តីពីដំណើរការរៀបចំ GOP27 Water and Climate Pavilion, ប្រជុំស្តីពីការចាប់ផ្តើមពង្រឹងការចូលរួមជាមួយ SWA ទៅលើ Mutual Accountability Mechanism, និងប្រជុំស្តីពីវឌ្ឍនៈភាពការងាររបស់គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងនៅអាស៊ីអាគ្នេយ៍ជំហានទី០២។

### ១.៣.សកម្មភាពកម្មវិធីលើកកម្ពស់អនាម័យជនបទតាមរយៈថវិកាកម្មវិធី

- មន្ត្រីនាយកដ្ឋានបានចុះផ្សព្វផ្សាយ និងបើកវគ្គបណ្តុះបណ្តាលចំនួន២២លើកដោយផ្តោតសំខាន់លើកម្មវិធីលើកកម្ពស់អនាម័យជនបទតាមរយៈវិទ្យុចំនួន០៣លើក, រៀបចំវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជនបង្គោលអនាម័យ លើការងារលើកកម្ពស់អនាម័យចំនួន០៣លើកក្នុងខេត្តក្រចេះព្រះវិហារនិងសៀមរាបមានអ្នកចូលរួមចំនួន១៣២នាក់, ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យប្រតិបត្តិអនាម័យល្អនៅតាមគ្រួសារទាំង១៦ខេត្ត និងបានចុះពិនិត្យមើលទីតាំងដាក់បង្គន់អនាម័យនៅតាមភូមិគោលដៅទាំង១៣ខេត្ត, ចុះផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្តីពីអនាម័យក្នុងបរិស្ថានប្រឈមសម្រាប់គ្រួសារជនបទ នៅខេត្តកំពង់

ត្បូងឃ្មុំ កំពង់ចាម ត្បូងឃ្មុំ កោះកុង ក្រចេះ និងសៀមរាបដែលមានអ្នកចូលរួមចំនួន១៧០នាក់, បានរៀបចំផ្សព្វផ្សាយសារលិខិតសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរទិវាជាតិលើកកម្ពស់អនាម័យជនបទ លើកទី១៣ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងប្រជុំមហាជនតាមបណ្ដាខេត្ត ស្រុក និងឃុំ, និងការសាងសង់បង្គន់អនាម័យចំនួន២៧១៩បង្គន់ក្នុងឆ្នាំ២០២២ក្រោមថវិការដ្ឋ។

**១.៤.សកម្មភាពកម្មវិធីសហគមន៍ដឹកនាំអនាម័យ(Community Led Total Sanitation)**

- មន្ត្រីនាយកដ្ឋានបានរៀបចំប្រជុំ បើកវគ្គបណ្ដុះបណ្ដាល ចូលរួមប្រជុំ និងសិក្ខាសាលាចំនួន ៧០លើកដោយផ្ដោតលើ៖ បណ្ដុះបណ្ដាលការសាងសង់បង្គន់អនាម័យលូភ្លោះលើផ្ទះ, ចុះបំផុសនិងជម្រុញការងារសាងសង់បង្គន់អនាម័យ, ប្រជុំជាមួយអង្គការUnicef និង WaterAid ក្នុងការពន្លឿនផែនការ (ODF), ប្រជុំក្រុមការងារ PWG-RWSSH ស្ដីពីស្ថានភាពទឹកស្អាតនិងអនាម័យ ការផ្ទៀងផ្ទាត់ភូមិនិងស្រុកODF និងរៀបចំប្រព័ន្ធODFខេត្ត, ប្រជុំជាមួយអង្គការ Washsdo ពិភាក្សាលើការប្រមូលទិន្នន័យការប្រតិបត្តិអនាម័យក្នុងបរិស្ថានប្រឈម, ប្រជុំក្រុមការងារ DWG-RWSSH ស្ដីពីបញ្ហាប្រឈមនិងដំណោះស្រាយការអនុវត្តផែនការODFនិងរាយការណ៍ពីស្ថានភាពអនាម័យ, ចូលរួមប្រជុំគម្រោងPHEស្ដីពីយុទ្ធសាស្រ្តការអនុវត្តកម្មវិធីអនាម័យ, ចុះផ្សព្វផ្សាយពីគោលការណ៍ណែនាំកម្មវិធីទឹកស្អាតនិងអនាម័យសម្រាប់ជនពិការនិងមនុស្សចាស់, ប្រជុំជាមួយអង្គការUNICEFរៀបចំមេរៀនទឹកស្អាតនិងអនាម័យមានភាពធន់ទ្រាំទៅនឹងអាកាសធាតុសម្រាប់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ខេត្ត, ប្រជុំជាមួយមន្ទីរអភិវឌ្ឍន៍ខេត្ត និងអង្គការដៃគូពិភាក្សាលើគោលការណ៍ឧបត្ថម្ភធនដល់គ្រួសារក្រីក្រសាងសង់បង្គន់អនាម័យ, ចុះសិក្សាទីតាំងសាងសង់បង្គន់អនាម័យតាមព្រំដែនសម្រាប់ពលករចំណាកស្រុកទៅប្រទេសថៃ, ចូលរួមប្រជុំNAPIIនិងត្រួតពិនិត្យវឌ្ឍនភាពការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ២០១៤-២០២៥, ប្រជុំអន្តរក្រសួងជាមួយអង្គការដៃគូពិនិត្យផែនការសកម្មភាពជាតិ ស្ដីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០២១-២០២៥, ប្រជុំពិភាក្សាលើសេចក្ដីព្រាងគោលការណ៍ណែនាំជាតិស្ដីពី ការគ្រប់គ្រងអនាម័យស្ត្រីនិងកុមារីពេលមានរដូវ, ប្រជុំជាមួយក្រសួងសុខាភិបាលដើម្បីពិនិត្យលទ្ធផលនៃការស្ទង់មតិការវិភាគនិងវាយតម្លៃជាសកលលើស្ថានភាពអនាម័យនិងទឹកបរិភោគ, ប្រជុំជាមួយមន្ត្រីសវនកម្មជាតិ(NAA) អំពីលំហូរការងារនិងយន្តការដឹកនាំសម្របសម្រួលនៃវិស័យអនាម័យជនបទ, ប្រជុំជាមួយមន្ត្រីថ្នាក់ក្រោមជាតិ និងអង្គការUNICEFពិនិត្យមើលស្ថានភាពបង្គន់សង់ថ្មី, ប្រជុំពិនិត្យផែនការឃុំODF និងការបែងចែកថវិកាឃុំសម្រាប់កម្មវិធីទឹកស្អាតនិងអនាម័យ, ប្រជុំលើកទី៣៤ក្រុមការងារទឹកស្អាត និងអនាម័យបង្ហាញពីលទ្ធផលប្រជុំថ្នាក់រដ្ឋមន្ត្រីនៅប្រទេសឥណ្ឌូនេស៊ី, ចុះផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្ដីពីការអនុវត្ត(CLTS) និងអនាម័យក្នុងបរិស្ថានប្រឈម, ចូលរួមប្រជុំស្ដីពីការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យក្នុងបរិស្ថានប្រែប្រួលអាកាសធាតុនិងបរិយាប័ន្ន, ចុះបំផុសសកម្មភាពអនាម័យតាមខ្នងផ្ទះ និងប្រមូលព័ត៌មានទីផ្សារអនាម័យ, រៀបចំប្រជុំពិគ្រោះយោបល់ការលើកកម្ពស់អនាម័យ

និងផ្គត់ផ្គង់ទឹកស្អាតតាមរយៈការប្រឡងប្រណាំងភូមិឃុំសង្កាត់មានសុវត្ថិភាព, និងការសាងសង់បង្គន់អនាម័យសរុបចំនួន២៦០៣៦បង្គន់ក្នុងឆ្នាំ២០២២ក្នុងខេត្តចំនួន០៦ (ថវិកាUnicef)។

**១.៥. សកម្មភាពការងារ Facebook និងអង្គការ East Meet West (EMW)**

- មន្ត្រីនាយកដ្ឋានបានផ្សព្វផ្សាយវីដេអូសារអប់រំអនាម័យ និងវិធានការទប់ស្កាត់ជម្ងឺកូវីដ១៩ ដល់ ខេត្តគោលដៅទាំង០៦របស់អង្គការUNICEFតាមរយៈគេហទំព័រFacebookរបស់នាយកដ្ឋាន
- មន្ត្រីនាយកដ្ឋានបានសហការជាមួយអង្គការ(EMW)ចុះផ្សព្វផ្សាយ និងជម្រុញការងារសាងសង់បង្គន់ដល់គ្រួសារក្រីក្រឆ្នាំ២០២២សរុបចំនួន១៥៣៣បង្គន់ (ថវិកាអង្គការEMW) ក្នុងនោះបង្គន់លូមួយជួរចំនួន៧៨៤បង្គន់ បង្គន់លូឆ្លាស់ពីរជួរចំនួន៣៩០បង្គន់ និងបង្គន់កែពីលូមួយជួរទៅលូពីរជួរចំនួន៣៥៩បង្គន់ ស្ថិតក្នុងខេត្តគោលដៅចំនួន០៩ (ត្បូងឃ្មុំ ពោធិ៍សាត់ក្រចេះព្រៃវែងកំពង់ចាមកំពង់ឆ្នាំងតាកែវកំពង់ស្ពឺនិងកំពត)។

**២. សកម្មភាពការងារការិយាល័យថែទាំសុខភាពជនបទ(ថ្នាក់ខេត្ត)**

- បានសាងសង់បង្គន់ចាក់ទឹកចំនួន១៥១បង្គន់ (ថវិការដ្ឋ/អង្គការបណ្ដុះកុមារ) បានផ្ដល់ចានបង្គន់ដល់ប្រជាពលរដ្ឋជាលក្ខណៈឯកជនចំនួន៣៥៥បង្គន់ និងផ្ដល់បង្គន់សាធារណៈចំនួន៥០បង្គន់ (ថវិការដ្ឋ)និងបានអប់រំអនាម័យដល់ប្រជាពលរដ្ឋចំនួន១១៥៤នាក់។

## II. បញ្ហាប្រឈម

- ប្រជាពលរដ្ឋនៅតែមានទស្សនៈពឹងផ្អែកលើជំនួយទើបនាំគ្នាសាងសង់បង្គន់
- ប្រជាជនក្រីក្រនៅមិនទាន់បានទទួលផលប្រយោជន៍ច្រើនពីកម្មវិធីលើកកម្ពស់អនាម័យក្នុងភូមិនីមួយៗ
- ការអនុវត្តគម្រោងប្រចាំឆ្នាំដែលគាំទ្រដោយថវិកាជាតិមានរយៈពេលខ្លី សម្រាប់ជម្រុញឱ្យប្រជាជនមានការផ្លាស់ប្ដូរទម្លាប់ដើម្បីប្រតិបត្តិអនាម័យល្អ
- ឥរិយាបទប្រឈមនឹងគ្រោះថ្នាក់ពេលបន្ទោបង់ពាសវាលពាសកាល មិនមានទម្លាប់ផឹកទឹកមានសុវត្ថិភាព និងការលាងសំអាតដៃមិនបានត្រឹមត្រូវ
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល និងការផ្គត់ផ្គង់បរិក្ខាអនាម័យ)
- សមត្ថភាពចូលរួមផ្ដល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះមានស្ថានភាពលំបាក ខ្វះទឹក ឬគ្រោះធម្មជាតិ
- ការធ្លាក់ចុះប្រភពថវិកាជាតិនិងពីអង្គការដៃគូនានាក្នុងការអនុវត្តកម្មវិធីអនាម័យជនបទ។

## III. មេរៀនបទពិសោធន៍

### ១.ចំណុចខ្លាំង

- មានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការលើកកម្ពស់អនាម័យជនបទនិងមានទិសដៅនិងផែនការក្នុងការអនុវត្តគម្រោង
- ការខិតខំឱ្យមានការគាំទ្រទាំងថវិកាគោលនយោបាយយុទ្ធសាស្ត្រ និងឆន្ទៈគាំទ្រដល់បញ្ហាលើកកម្ពស់អនាម័យជនបទ

- មានការគាំទ្រនិងសហការគ្នាល្អពីដៃគូអភិវឌ្ឍទាំងថវិកាបច្ចេកទេសលើការអនុវត្តគម្រោងការចែករំលែកបទពិសោធន៍និងព័ត៌មាននានា
- មានការអភិវឌ្ឍឯកសារ និងគោលការណ៍ផ្សេងៗក្នុងការដឹកនាំអនុវត្តគម្រោងនានានៃការលើកកម្ពស់អនាម័យជនបទ
- បុគ្គលិកម្នាក់ៗក្នុងនាយកដ្ឋានមានឆន្ទៈខ្ពស់ក្នុងការរួមគ្នាធ្វើការជំរុញ និងលើកកម្ពស់អនាម័យជនបទ។

## ២.ចំណុចខ្វះខាត

- ការចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- ថវិកាជាតិនៅមានកម្រិតដើម្បីគាំទ្រវិស័យលើកកម្ពស់អនាម័យជនបទ
- ពេលវេលាអនុវត្តគម្រោងប្រចាំឆ្នាំដែលគាំទ្រដោយថវិកាជាតិមានរយៈពេលខ្លីសម្រាប់ជំរុញឱ្យប្រជាជនមានការផ្លាស់ប្តូរទម្លាប់នាំមកនូវការប្រតិបត្តិអនាម័យល្អ
- ការគាំទ្រ និងការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត
- ខ្វះខាតផ្នែកធនធានមនុស្សសម្រាប់បំរើការនៅក្នុងកម្មវិធីលើកកម្ពស់អនាម័យជនបទជា ពិសេសអ្នកបច្ចេកទេសដែលមានសមត្ថភាពនិងបទពិសោធន៍
- គម្រោងខ្លះមានការថយចុះការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការដៃគូអភិវឌ្ឍ។

## ៣. សំណូមពរ

- ស្នើសុំថ្នាក់ដឹកនាំជួយគៀគរកធនធានពីថវិកាជាតិនិងអង្គការដៃគូអភិវឌ្ឍសម្រាប់គាំទ្រ កម្មវិធីនានា ស្ថិតនៅក្រោមនាយកដ្ឋានដើម្បីបានបន្តដំណើរការ
- រៀបចំការផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទឱ្យបានទូលំទូលាយនៅតាមបណ្តារាជធានី-ខេត្តដោយមានការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិដើម្បីជម្រុញការអនុវត្តមានភាពរលូននិងប្រសិទ្ធភាពខ្ពស់
- ការអនុវត្តកម្មវិធីលើកកម្ពស់អនាម័យ ដែលគាំទ្រដោយដៃគូអភិវឌ្ឍនានាត្រូវផ្អែកលើផែនការសកម្មភាពជាតិក្នុងការជម្រុញលើកកម្ពស់អនាម័យជនបទ។

# IV. ទិសដៅការងារឆ្នាំ ២០២៣

- បន្តប្រជុំការងារបច្ចេកទេសMISថ្នាក់ជាតិនិងជាមួយអង្គការដៃគូដើម្បីពិនិត្យនិងជ្រើសរើសសូចនាករសម្រាប់បង្កើត Application MIS និងប្រមូលនិងចងក្រងទិន្នន័យMISត្រីមាសទី០៤
- បន្តបណ្តុះបណ្តាលពីទឹកស្អាតនិងអនាម័យដែលមានភាពធន់ទ្រាំទៅនឹងអាកាសធាតុ
- បន្តចូលរួមពិភាក្សាការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងអនាម័យស្ត្រី និងកុមារីពេលមានរដូវ
- បន្តផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ។
- បន្តរៀបចំឯកសារគោលការណ៍ណែនាំ ស្តីពីការផ្គត់ផ្គង់ទឹកការសំអាត និងអនាម័យជនបទដែលបានសហការជាមួយអង្គការ WaterAid សម្រាប់គាំទ្រដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ។

- បន្តការរៀបចំផែនការនិងកិច្ចសហការជាមួយអង្គការនានា ជាពិសេសអង្គការPlan International Cambodia, UNICEF, WaterAid លើកម្មវិធីលើកកម្ពស់អនាម័យជនបទ, អង្គការ IDE East Meets West លើកម្មវិធីទីផ្សារអនាម័យ, និងអង្គការEMB លើកម្មវិធីអនាម័យក្នុងតំបន់បរិស្ថានប្រឈម។
- រៀបចំផ្សព្វផ្សាយផែនការសកម្មភាពជាតិជំហានទី០២(២០១៩-២០២៣)ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទនៅតាមបណ្តាខេត្តឲ្យបានទូលំទូលាយ។

## សេចក្តីសន្និដ្ឋាន

ការអនុវត្តកម្មវិធីលើកកម្ពស់អនាម័យគឺជាសកម្មភាពមួយដែលទាមទារពេលវេលាវែង ពីព្រោះយើងត្រូវធ្វើការផ្លាស់ប្តូរទម្លាប់និងផ្នត់គំនិតរបស់ប្រជាជន។ ទន្ទឹមនេះការអនុវត្តការងារទាមទារឱ្យមានការសម្របសម្រួលនិងឯកភាពគ្នាពីគ្រប់ភាគីពាក់ព័ន្ធដើម្បីជំរុញ និងលើកកម្ពស់អនាម័យនៅជនបទឱ្យមានភាពរលូន។ ដើម្បីឱ្យការអនុវត្តការងារនេះកាន់តែមានភាពល្អប្រសើរនិងប្រសិទ្ធភាពខ្ពស់នាយកដ្ឋានថែទាំសុខភាពជនបទនឹងបន្តកែលម្អគុណភាពកម្មវិធីផ្គត់ផ្គង់ទឹកការសំអាត និងអនាម័យជនបទប្រកបដោយនិរន្តរភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងដៃគូពាក់ព័ន្ធដូចជា ម្ចាស់ជំនួយ ភ្នាក់ងាររដ្ឋាភិបាល និងប្រជាជនមូលដ្ឋាន និងជាពិសេសបន្តការអនុវត្តយុទ្ធសាស្ត្រជាតិឱ្យបានទូលំទូលាយ និងស៊ីជម្រៅគ្រប់ដណ្តប់ទូទាំងប្រទេស។